ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

គណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ

លេខ ១៩៧ គល

បានពិនិត្យត្រឹមត្រូវ

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## សេចក្តីជូនដំណឹង

## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ

## ការងារសាងសង់អគារស្នាក់នៅសហគមន៍ភូមិអណ្តូង ធ្វើពីបេតុងអាម៉េ ជាន់ផ្ទាល់ដី ដំបូលប្រក់ស័ង្កសី ទំហំ ០៤ម x ០៥ម ចំនួន ១៦០ផ្ទះ និងហេដ្ឋារចនាសម្ព័ន្ធ ស្ថិតក្នុងភូមិអណ្តូង សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ជូនរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ ២០១៧

រដ្ឋបាលរាជធានីភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក (គិតទាំងសហគ្រាសឯកត្តបុគ្គល) និងក្រុមហ៊ុនបរទេសទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា រដ្ឋបាលរាជធានីភ្នំពេញនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារសាងសង់អគារស្នាក់នៅសហគមន៍ភូមិអណ្តូង ធ្វើពីបេតុងអាម៉េ ជាន់ផ្ទាល់ដី ដំបូលប្រក់ស័ង្កសី ទំហំ ០៤ម x ០៥ម ចំនួន ១៦០ផ្ទះ និងហេដ្ឋារចនាសម្ព័ន្ធ ស្ថិតក្នុងភូមិអណ្តូង សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ជូនរដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៧ ។

រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានីភ្នំពេញ ដែលមានអាសយដ្ឋានលេខ៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ(ទូរស័ព្ទទាក់ទងលេខ ០១៦ ៧៥៥០០៥)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ០៨:០០ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៧ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ០៩:០០ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០១៧

អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងជា

ប្រធានគណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ

ឃួង ស្រេង

ចម្លងជូន ៖

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ